# បទបង្ហាញស្តីពី

# ភាតព្វកិច្ចគណនេយ្យនិងសវនកម្ម សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

រៀបចំដោយ ៖ និយ័តករគណនេយ្យនិងសវនកម្ម

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤

# មាតិកា

១. ការកាន់បញ្ជីគណនេយ្យ

២. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

៣. ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ

៤. ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

៥. កម្រៃសេវាសាធារណៈ

# ១. ការកាន់បញ្ជីគណនេយ្យ

**បញ្ជីគណនេយ្យ** សំដៅដល់សៀវភៅ/បញ្ជីសម្រាប់ការកត់ត្រាប្រតិបត្តិការគណនេយ្យដែលរួមមានសក្ខីប័ត្រគណនេយ្យ ទិន្នានុលេខន៍ សៀវភៅធំជាដើម។

១.១. បញ្ជីគណនេយ្យ មានជាអាទិ៍÷

- បញ្ជី/សៀវភៅទិញ
- បញ្ជី/សៀវភៅលក់
- បញ្ជី/សៀវភៅទទួលប្រាក់
- បញ្ជី/សៀវភៅបង់ប្រាក់
- បញ្ជី/សៀវភៅចាំបាច់ផ្សេងទៀត...

# ១. ការកាន់បញ្ជីគណនេយ្យ (ត)

## ១.២. ភាសាក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ ៖

អង្គភាពមិនស្វែងរកប្រាក់ចំណេញ អាចប្រើភាសាអង់គ្លេស ៖

- ប្រព័ន្ធគណនេយ្យកុំព្យូទ័រ និងប្រព័ន្ធកុំព្យូទ័រ ពាក់ព័ន្ធសម្រាប់ការកត់ត្រាប្រតិបត្តិការគណនេយ្យជាភាសាអង់គ្លេស។

  ឧទាហរណ៍ ៖ QuickBooks, Peachtree ,Simply Accounting ជាដើម។

- ត្រូវជូនដំណឹងពីការប្រើប្រាស់ភាសាអង់គ្លេសមក **ន.គ.ស.**

# ១. ការកាន់បញ្ជីគណនេយ្យ (ត)

## ១.២. ភាសាសម្រាប់ឯកសារគាំទ្រ ÷

ឯកសារគាំទ្រដល់កិច្ចបញ្ជិកាគណនេយ្យ÷

- ត្រូវជាភាសាខ្មែរ ឬ អាចប្រើភាសាអង់គ្លេសអមជាមួយភាសាខ្មែរបាន => សម្រាប់ឯកសារគណនេយ្យផ្ទៃក្នុង
- អាចជាភាសាអង់គ្លេស => សម្រាប់
  - ឯកសារគណនេយ្យដែលបង្កើតចេញដោយប្រព័ន្ធកុំព្យូទ័រដែលមិនអាចប្រើជាភាសាខ្មែរបាន
  - ឯកសារផ្តល់ដោយដៃគូធុរកិច្ចបរទេស ឬ សម្រាប់ធុរកិច្ចជាមួយដៃគូបរទេស ឬអង្គការដៃគូ ឬម្ចាស់ជំនួយបរទេស។
  - ចំពោះឯកសារគាំទ្រការធ្វើធុរកិច្ច ឬប្រតិបត្តិការក្រៅពីភាសាខ្មែរ និងភាសាអង់គ្លេសត្រូវបកប្រែឯកសារទាំងនោះជាភាសាខ្មែរឬភាសាអង់គ្លេស។

# ១. ការកាន់បញ្ជីគណនេយ្យ (ត)

១. ៣. រូបិយបណ្ណក្នុងការកត់ត្រា៖

✓ អាចជ្រើសរើស រូបិយបណ្ណមុខងារអាចជាប្រាក់រៀល ឬ រូបិយបណ្ណបរទេសតាមគោលនយោបាយគណនេយ្យរបស់ខ្លួន។

១. ៤. ការិយបរិច្ឆេទគណនេយ្យ៖

- រយៈពេល ១២ ខែ គិតចាប់ពី ថ្ងៃទី១ មករា ដល់ ថ្ងៃទី៣១ ធ្នូ នៃឆ្នាំដដែល
- អង្គភាពថ្មី (គិតចាប់ផ្តើមពីថ្ងៃបង្កើតអង្គភាព ដល់ថ្ងៃទី៣១ ខែ ធ្នូ នៃឆ្នាំដដែល)
- អាចស្នើសុំបិទបញ្ជីគណនេយ្យនៅការិយបរិច្ឆេទគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ ក្នុងករណីពិសេស។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០៥......សហវ.......

ថ្ងៃ [illegible] ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ២០២១

## សារាចរណែនាំ
## ស្តីពី
## ការប្រើប្រាស់ភាសា និង រូបិយប័ណ្ណ
## ក្នុងបញ្ជីគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងក្នុងគោលបំណងសម្រួលដល់ការធ្វើធុរកិច្ចរបស់ធុរជនដោយអាចរក្សាបានគុណតម្លៃនៃភាសាខ្មែរ និងប្រាក់រៀលព្រមទាំងអាចធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំ ដូចខាងក្រោម÷

១-សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ អាចប្រើភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងៗទៀតសម្រាប់ការកត់ត្រាប្រតិបត្តិការគណនេយ្យ ក្នុងករណីដែលសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញពុំទាន់អាចរកបានប្រព័ន្ធកុំព្យូទ័រទាំងនោះ ដែលអាចប្រើភាសាខ្មែរបានតាមតម្រូវការប្រតិបត្តិការរបស់ខ្លួន។ សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញពុំបានតម្រូវឱ្យស្នើសុំលើការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធកុំព្យូទ័រទាំងនោះឡើយ ប៉ុន្តែសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវជូនដំណឹងជាលាយល័ក្ខអក្សរមក**និយ័តករគណនេយ្យនិងសវនកម្ម** ដោយបញ្ជាក់ឱ្យបានច្បាស់អំពីឈ្មោះ និងប្រភពនៃប្រព័ន្ធកុំព្យូទ័រដែលកំពុងប្រើនោះ។

២-ឯកសារគណនេយ្យផ្ទៃក្នុងដែលគាំទ្រដល់កិច្ចបញ្ជិកាគណនេយ្យ ត្រូវជាភាសាខ្មែរ។ ឯកសារទាំងនេះ អាចត្រូវ បានអនុញ្ញាតឱ្យប្រើភាសាអង់គ្លេសអមជាមួយភាសាខ្មែរបាន។ ចំពោះឯកសារគណនេយ្យដែលបង្កើតចេញពីប្រព័ន្ធកុំព្យូទ័រដែលមិនអាចប្រើភាសាខ្មែរបានដូចមានចែងក្នុងចំណុចទី ១ខាងលើ និងឯកសារគណនេយ្យដែលត្រូវបានរៀបចំនិងផ្តល់ដោយ ដៃគូធុរកិច្ចបរទេស ឬដោយអង្គការដៃគូ ឬម្ចាស់ជំនួយបរទេស ឬសម្រាប់ធុរកិច្ចជាមួយដៃគូធុរកិច្ចបរទេស ឯកសារទាំងនោះអាចជាភាសាអង់គ្លេសបាន។ ក្នុងករណីឯកសារគាំទ្រការធ្វើធុរកិច្ច ឬប្រតិបត្តិការក្រៅពីភាសាខ្មែរ និងភាសាអង់គ្លេស សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវទទួលខុសត្រូវបកប្រែឯកសារទាំងនោះទៅជាភាសាខ្មែរ ឬភាសាអង់គ្លេស ដោយមានប្រថាប់ត្រារបស់សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញផ្ទាល់។

<u>ឧទាហរណ៍</u>÷ កិច្ចសន្យាទិញ-លក់ដែលត្រូវបានរៀបចំជាភាសាបរទេស (ក្រៅពីភាសាអង់គ្លេស) ដូចនេះ សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវបកប្រែកិច្ចសន្យានោះជាភាសាខ្មែរ ឬភាសាអង់គ្លេស ដោយមាន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ហត្ថលេខាទទួលស្គាល់លើខ្លឹមសារនៃអត្ថបទបកប្រែរបស់ម្ចាស់សហគ្រាស ឬអ្នកមានសិទ្ធិ និងមានប្រថាប់ត្រារបស់សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញផ្ទាល់។

៣-សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ អាចជ្រើសរើសរូបិយប័ណ្ណមុខងារជាប្រាក់រៀល ឬរូបិយប័ណ្ណបរទេសតាមគោលនយោបាយគណនេយ្យរបស់ខ្លួនដោយអនុលោមតាមស្តង់ដាគណនេយ្យជាធរមាន សម្រាប់កត់ត្រាប្រតិបត្តិការគណនេយ្យប្រចាំថ្ងៃ។

៤-សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជាភាសាខ្មែរ និងបង្ហាញជាប្រាក់រៀល ឬបង្ហាញជាប្រាក់រៀលផងនិងរូបិយប័ណ្ណបរទេសផង។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជាប្រាក់រៀល សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវអនុវត្តតាមការណែនាំក្នុងស្តង់ដាគណនេយ្យជាធរមាន ដោយប្រើអត្រាប្តូរប្រាក់ផ្លូវការដែលបានបោះផ្សាយដោយធនាគារជាតិនៃកម្ពុជា ហើយត្រូវបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនោះ មកនិយ័តករគណនេយ្យនិងសវនកម្ម តាមសេចក្តីណែនាំរបស់ និយ័តករគណនេយ្យនិងសវនកម្មដើម្បីជាកម្មវត្ថុនៃការរក្សាទុក និងការត្រួតពិនិត្យលើកម្រិតអនុលោមភាព ស្របតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

៥-ចំពោះសហគ្រាសដែលធ្វើប្រតិបត្តិការប្រេងកាតនៅក្នុងដែនអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមប្រកាស ៥៣៦ សហវ.ប្រក ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការណែនាំអនុវត្តបទប្បញ្ញត្តិស្តីពី ពន្ធលើប្រតិបត្តិការប្រេងកាត។

៦-ក្នុងអំឡុងពេលនៃការអនុវត្តសារាចរនេះ និយ័តករគណនេយ្យនិងសវនកម្ម ត្រូវពិនិត្យ តាមដាន និងវាយតម្លៃលើលទ្ធភាពនៃការកាន់បញ្ជីគណនេយ្យជាភាសាខ្មែរ និងប្រាក់រៀល ។

៧- និយ័តករគណនេយ្យនិងសវនកម្ម អាចស្នើឡើងនូវវិធានចាំបាច់នានាបន្ថែមសម្រាប់ការអនុវត្តសារាចរនេះ។

ទទួលបានសារាចរណែនាំនេះ និយ័តករគណនេយ្យនិងសវនកម្ម អគ្គនាយកដ្ឋានពន្ធដារ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ស្ថាប័នពាក់ព័ន្ធ សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវសហការអនុវត្តសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ តទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

<u>កន្លែងទទួល ÷</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ២. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

**ស្តង់ដាគណនេយ្យ÷**

- សហគ្រាសទទួលខុសត្រូវជាសាធារណៈ ត្រូវប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (CIFRS) ( ឧ. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ, ធនាគារពាណិជ្ជ ឬគ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ...)
- សហគ្រាសមិនទទួលខុសត្រូវជាសាធារណៈ អាចប្រើស្តង់ដាគណនេយ្យ CIFRS ឬស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម (CIFRS for SMEs)
- អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវប្រើប្រាស់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ  (CFRS For NFPEs)

CIFRS For SMEs

CIFRS

CIFRS For NFPEs

Entities under the Law on Associations and NGOs













35 Sections







CIFRS : 16

CIAS : 25

# ២. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

❖ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យស្របតាមស្តង់ដាគណនេយ្យជាធរមានឱ្យបានរួចរាល់ក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

- អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវអនុវត្តតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (CFRS For NFPEs)។

- អង្គភាពមិនស្វែងរកប្រាក់ចំណេញ អាចអនុវត្តតាមស្តង់ CIFRS for SMEs ឬ CIFRS ប៉ុន្តែត្រូវជូនដំណឹងមក **ន.គ.ស.**។

# ២. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

**ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (CFRS For NFPEs)** ចែកជាភាគ ក និង ភាគ ខ÷

- **ភាគ ក ÷លក្ខខណ្ឌចាំបាច់**

  ផ្នែកទី១÷ សេចក្តីណែនាំ

  ផ្នែកទី២÷ គោលបំណងនៃការរៀបចំរបាយការណ៍ និងទិដ្ឋភាពទូទៅនៃលក្ខខណ្ឌចាំបាច់សម្រាប់ការរាយការណ៍

  ផ្នែកទី៣÷ ព័ត៌មានរបស់អង្គភាព

  ផ្នែកទី៤÷ របាយការណ៍ចំណូល និងចំណាយ

  ផ្នែកទី៥÷ កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

  ផ្នែកទី៦÷ ឧទាហរណ៍គំរូ

  ផ្នែកទី៧÷ សន្ទានុក្រម
- **ភាគ ខ ÷ ការរៀបចំអន្តរកាល**

មគ្គុទ្ទេសក៏ពន្យល់

គំរូរបាយការណ៍បន្ថែម និងសេចក្តីណែនាំពាក់ព័ន្ធក្នុងការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (CFRS for NFPEs)

បោះផ្សាយដោយ ក្រុមប្រឹក្សាជាតិគណនេយ្យ

ទាក់ទងនឹងការរាយការណ៍សម្រាប់ការិយបរិច្ឆេទចាប់ផ្តើមពី ឬបន្ទាប់ពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨

មគ្គុទ្ទេសក៏ពន្យល់នេះផ្តល់ជូននូវគំរូរបាយការណ៍មួយ និងសេចក្តីណែនាំពាក់ព័ន្ធសម្រាប់ការអនុវត្តបន្ថែមសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលកំពុងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (CFRS for NFPEs)។

មគ្គុទ្ទេសក៏ពន្យល់នេះគឺជាឯកសារពន្យល់មួយ និងពុំមានការតម្រូវផ្នែកច្បាប់នោះទេ។

1

©រក្សាសិទ្ធិ

## មាតិកា

ផ្នែកទី១÷ សេចក្តីណែនាំ
ផ្នែកទី២÷ គោលបំណងនៃការរៀបចំរបាយការណ៍ និងទិដ្ឋភាពទូទៅនៃលក្ខខណ្ឌចាំបាច់សម្រាប់ការរាយការណ៍
ផ្នែកទី៣÷ ព័ត៌មានរបស់អង្គភាព
ផ្នែកទី៤÷ របាយការណ៍ចំណូល និងចំណាយ
ផ្នែកទី៥÷ កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

# ២. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

- ភាសា៖ ត្រូវតែជាភាសាខ្មែរ។
- រូបិយបណ្ណ៖ ត្រូវតែជាប្រាក់រៀល ឬ (រៀល+រូបិយបណ្ណបរទេស)

**កាតព្វកិច្ចផ្សេងទៀត៖**

- រក្សាទុកក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ គិតពីកាលបរិច្ឆេទនៃការបង្កើតឯកសារ
- *ធ្វើជាមូលដ្ឋានសម្រាប់បំពេញកាតព្វកិច្ចសារពើពន្ធ ។*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ.០០១/២៤ .....ន.គ.ស/.ណ.ដ.ណ.

# សេចក្តីជូនដំណឹង

## ស្តីពី

## អត្រាប្តូរប្រាក់សម្រាប់ប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០២៣

អត្រាប្តូរប្រាក់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣៖ ១ ដុល្លារអាមេរិក = ៤ ០៨៥ រៀល

អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ២០២៣៖ ១ ដុល្លារអាមេរិក = ៤ ១១០ រៀល

ថ្ងៃអង្គារ ៦ រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២ ខែមករា ឆ្នាំ២០២៤

និយ័តករគណនេយ្យនិងសវនកម្ម

***សំគាល់៖** ចំពោះសហគ្រាស ឬ អង្គភាពដែលប្រើរូបិយប័ណ្ណមុខងារខុសពីប្រាក់ដុល្លារសហរដ្ឋអាមេរិក សូមធ្វើការគណនាអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ ដោយយកអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃជារូបិយប័ណ្ណនោះដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា បូកបញ្ចូលគ្នា គិតចាប់ពីកាលបរិច្ឆេទបើកបញ្ជីគណនេយ្យរហូតដល់កាលបរិច្ឆេទបិទបញ្ជីគណនេយ្យនៃការិយបរិច្ឆេទគណនេយ្យរបស់សហគ្រាស ឬ អង្គភាព រួចចែកនឹង ៣៦៥ ថ្ងៃ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

# ៣. ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ

- អង្គភាពមិនស្វែងរកប្រាក់ចំណេញ ស្ថិតក្នុងលក្ខណៈវិនិច្ឆ័យ ទាំង ២ ខាងក្រោម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ÷

  ១. ចំណាយប្រចាំឆ្នាំសរុប ចាប់ពី ២ ប៊ីលានរៀល និង

  ២. ចំនួនកម្មករនិយោជិក ចាប់ពី ២០ នាក់ ឡើងទៅ។

  (ដោយយោងតាមចំនួនកម្មករនិយោជិតមធ្យមភាគ ដែលមានក្នុងឆ្នាំ)

- *ករណីអង្គភាពមិនស្ថិតក្នុងលក្ខខណ្ឌវិនិច្ឆ័យទាំងពីរខាងលើ អាចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត។*

# ៣. ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ

❖ អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ដោយត្រូវបញ្ចប់ការងារធ្វើសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យ មិនឱ្យហួសរយៈពេល៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

# ៣. ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ

សេចក្តីជូនដំណឹង ស្តីពីបច្ចុប្បន្នភាពនៃបញ្ជីក្រុមហ៊ុនដែលទទួលបាននីតិសម្បទា ផ្តល់សេវាវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០២៤

# ៤. ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

❖ អង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស. តាមប្រព័ន្ធអនឡាញ -E-Filing System (https://efiling-nfpes.acar.gov.kh/) ៖**

- មិនជាប់លក្ខខណ្ឌក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ មានកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ប្រចាំឆ្នាំមក **ន.គ.ស. មិនឱ្យហួសរយៈពេល ៣ខែ ១៥ ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ។
- ជាប់លក្ខខណ្ឌក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ មានកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ដាក់រងសវនកម្មឯករាជ្យរួចមក **ន.គ.ស. មិនឱ្យហួសរយៈពេល ៦ខែ ១៥ ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០៣៧៨/២៣ ន.គ.ស/សណ.៣.

*ថ្ងៃពុធ ១៥កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧*

*រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ២០២៣*

**សេចក្តីជូនដំណឹង**

**ស្តីពី**

**កាតព្វកិច្ចនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣**

**មកនិយ័តករគណនេយ្យនិងសវនកម្ម**

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស.) **នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (អ.ស.ហ.) មានកិត្តិយស សូមជម្រាបជូនដល់ ម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ ជ្រាបថា÷ អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ (ហៅកាត់ថា អង្គភាព) ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ ស្របតាមស្តង់ដាគណនេយ្យជាធរមាន មក **ន.គ.ស.** តាមពេលវេលាដូចខាងក្រោម÷

**ទី១.** <u>សហគ្រាស និងអង្គភាព ដែលមិនរងសវនកម្មឯករាជ្យ</u> ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** **មិនឱ្យហួសថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៤**។ សហគ្រាស និងអង្គភាពដែលត្រូវបានអនុញ្ញាតឱ្យបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** មិនឱ្យហួសរយៈពេល **៣ខែ បូក ២០ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

**ទី២.** <u>សហគ្រាស និងអង្គភាព ដែលរងសវនកម្មឯករាជ្យ</u> ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មរួចមក **ន.គ.ស.** **មិនឱ្យហួសថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤**។ សហគ្រាស និងអង្គភាពដែលត្រូវបានអនុញ្ញាតឱ្យបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** មិនឱ្យហួសរយៈពេល **៦ខែ បូក ២០ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

*ជាមួយគ្នានេះ ដើម្បីជួយដល់សហគ្រាស និងអង្គភាព អនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មបានត្រឹមត្រូវ ជៀសផុតពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម **ន.គ.ស.** សូមរំលឹកអំពីកិច្ចការស្នូលមួយចំនួនដែលសហគ្រាស និងអង្គភាព ត្រូវអនុវត្តមានដូចខាងក្រោម÷*

១. ត្រូវកាន់បញ្ជីគណនេយ្យ ឱ្យបានត្រឹមត្រូវ

២. ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ឱ្យបានរួចរាល់មិនឱ្យហួស **រយៈពេល ៣ខែ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។ ស្តង់ដាគណនេយ្យជាធរមាន សំដៅដល់ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (Cambodia International Financial

ទំព័រ ១ នៃ ៣



Reporting Standards-CIFRS) ឬ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម (Cambodia International Financial Reporting Standards for Small and Medium Sized Entities-**CIFRS for SMEs**) ឬ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (Cambodian Financial Reporting Standards for Not-For-Profit Entities-**CFRS for NFPEs**)

៣. ត្រូវបញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្ម លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនឱ្យហួស **រយៈពេល ៦ខែ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ប្រសិនបើសហគ្រាស ឬ អង្គភាពនោះ ស្ថិតក្នុងលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងប្រកាសលេខ ៥៦៣ សហវ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។

៤. ត្រូវមានលេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុ (FIN) ដើម្បីអាចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន មក **ន.គ.ស.** ដោយត្រូវប្រើប្រាស់ប្រព័ន្ធអនឡាញ (e-filing system)។ សហគ្រាស ឬ អង្គភាព ដែលមិនទាន់មានលេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុពី **ន.គ.ស.** ត្រូវស្នើសុំតាមរយៈតំណភ្ជាប់ https://efiling.acar.gov.kh/auth/login ដោយត្រូវអនុវត្តតាមបែបបទ និងនីតិវិធីនៃការប្រើប្រាស់ប្រព័ន្ធអនឡាញ។

៥. ត្រូវដាក់លិខិតស្នើសុំផ្លាស់ប្តូរលេខ FIN មក **ន.គ.ស.** ឱ្យបានមុន **៦០ថ្ងៃ** នៃកាលបរិច្ឆេទផុតកំណត់ដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ ក្នុងករណីសហគ្រាស ឬ អង្គភាពបានប្រែប្រួលការចាត់ថ្នាក់ជាសហគ្រាស ឬ អង្គភាពរងសវនកម្មឯករាជ្យ ឬ មិនរងសវនកម្មឯករាជ្យ។ ការយឺតយ៉ាវក្នុងការស្នើសុំប្តូរលេខ FIN នឹងនាំដល់ការយឺតយ៉ាវនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** ដែលជាកម្មវត្ថុនៃការអនុវត្តពិន័យអន្តរការណ៍។

៦. សហគ្រាស ឬ អង្គភាព ត្រូវបង់កម្រៃសេវាសាធារណៈសម្រាប់ការទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុស្របតាមប្រកាសលេខ ០០១ អ.ស.ហ.ប្រ.ក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

៧. សហគ្រាស ឬ អង្គភាព អាចចាត់តាំងអ្នកតំណាងដើម្បីបំពេញកាតព្វកិច្ចគណនេយ្យនិងសវនកម្មជាមួយមន្ត្រី **ន.គ.ស.** បាន។ អ្នកតំណាងអាចជាបុគ្គលិកសហគ្រាស ឬ អង្គភាពផ្ទាល់ ឬជាក្រុមហ៊ុនគណនេយ្យ ឬ ជាក្រុមហ៊ុនសវនកម្មដែលមានអាជ្ញាបណ្ណនៅមានសុពលភាពពី **ន.គ.ស.** ។ រាល់អ្នកតំណាងត្រូវមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវពីម្ចាស់សហគ្រាស ឬ ប្រធានអង្គភាព។ ម្ចាស់សហគ្រាស និងប្រធានអង្គភាពត្រូវទទួលខុសត្រូវទាំងស្រុងចំពោះរាល់សកម្មភាពរបស់អ្នកតំណាងរបស់ខ្លួន។

៨. សហគ្រាស ឬអង្គភាព ត្រូវជ្រើសរើសក្រុមហ៊ុនគណនេយ្យ និង/ឬ សវនកម្មណាមួយ ដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬសវនកម្ម នៅមានសុពលភាព ពី **ន.គ.ស.** ដូចមាននៅក្នុងបញ្ជីភ្ជាប់មកជាមួយនឹងសេចក្តីជូនដំណឹងនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមន្ត្រីរបស់ **ន.គ.ស.** តាមរយៈប្រព័ន្ធតេឡេក្រាមដូចខាងក្រោម÷

- សហគ្រាសរងសវនកម្មឯករាជ្យ÷០៧០ ៩២៩ ២៣៧/០៧៧ ៨០៥ ៥៥២/០១០ ៦៩៤ ៦២/០១៦ ៥៩៨ ៣៨៦/០១០ ៧៣៦ ៨៣៥
- សហគ្រាសមិនរងសវនកម្មឯករាជ្យ÷ ០៩៣ ៩១៩ ១៩២/០៩៩ ៤២៩ ៣៩៨/០៧០ ៥៤៥ ៦៨៨/០៧០ ២១២ ២៣៦/០៦៩ ៥១៩ ៣៧១

ទំព័រ ២ នៃ ៣

- អង្គភាព÷ ០៨១ ៦៤៤ ៦៦៣/០៩២ ៦៨៨ ២៩៧/០៨៥ ៩០៤ ៨៤៨/០៨៥ ៤៤៤ ៤៨៨។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាព ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ចាប់ពីពេលនេះតទៅ។

**អគ្គនាយក**

**ប៊ូ ថារិទ**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់និយ័តករគណនេយ្យនិងសវនកម្ម



**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ..........................ន. គ. ស/ស.ជ.ណ.

ថ្ងៃអង្គារ ៤កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០២៤

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការផ្តល់ពេលវេលាបន្ថែម ក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣**
**សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលរងសវនកម្មឯករាជ្យ**
**មកនិយ័តករគណនេយ្យនិងសវនកម្ម**

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស) នៃ**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**(អ.ស.ហ.) សូមជម្រាបជូនម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ(អង្គភាព)ឱ្យបានជ្រាបថា: សម្រាប់សហគ្រាស និងអង្គភាពរងសវនកម្មឯករាជ្យ កាលបរិច្ឆេទនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ មក **ន.គ.ស.** នឹងត្រូវផុតកំណត់នៅ***ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤***ខាងមុខនេះ។ ដើម្បីសម្រួលដល់សហគ្រាស និងអង្គភាព ដែលរងសវនកម្មឯករាជ្យមួយចំនួន ដែលមិនទាន់បញ្ចប់នីតិវិធីជាស្ថាពរ **ន.គ.ស.** បានសម្រេចផ្តល់ពេលបន្ថែមចំនួន៣០(សាមសិប)ថ្ងៃ ក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ មក **ន.គ.ស.** តាមប្រព័ន្ធអនឡាញ (E-Filing System) និងអនុញ្ញាតឱ្យដាក់លិខិតពន្យារពេលដូចខាងក្រោម÷

១. សហគ្រាស និងអង្គភាព រងសវនកម្មឯករាជ្យ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ មក **ន.គ.ស.** មិនឱ្យហួស***ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤***។ សហគ្រាស និងអង្គភាព រងសវនកម្មឯករាជ្យ ដែលបានអនុញ្ញាតឱ្យបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ មក **ន.គ.ស.** មិនឱ្យហួសរយៈពេល ***៧ ខែ បូក ២០ថ្ងៃ*** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

២. សហគ្រាស និងអង្គភាពអាចដាក់លិខិតស្នើសុំពន្យារពេលការបញ្ចប់ការងារធ្វើសវនកម្មឯករាជ្យ មក **ន.គ.ស.** មិនឱ្យហួស**ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤** ដោយត្រូវបង់កម្រៃសេវាសាធារណៈស្របតាមប្រកាសលេខ ០០១ អ.ស.ហ ប្រក. ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមន្ត្រី **ន.គ.ស.** តាមរយៈលេខទូរសព្ទ និងតេឡេក្រាមដូចខាងក្រោម÷

- លោក ហាក់ សីហា ÷ ០៩៦ ៩ ១៩៩ ៩៩៨ សម្រាប់សហគ្រាស
- លោក យាន ផល្លា ÷ ០៨១ ៦៤៤ ៦៦៣ សម្រាប់អង្គភាព

**និយ័តករគណនេយ្យនិងសវនកម្ម** សង្ឃឹមយ៉ាងមុតមាំថា បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងនេះ ម្ចាស់សហគ្រាស និងអង្គភាព រងសវនកម្មឯករាជ្យទាំងអស់ នឹងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចគណនេយ្យនិងសវនកម្មបានទាន់ពេលវេលាតាមកាលកំណត់ប្រកបដោយការទទួលខុសត្រូវខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់និយ័តករគណនេយ្យនិងសវនកម្ម

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111

# ៥. តម្លៃសេវាសាធារណៈ

| ល.រ | ប្រភេទសេវា | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១ | លិខិតអនុញ្ញាតផ្លាស់ប្តូរការិយបរិច្ឆេទគណនេយ្យ | ១, ០០០,០០០ | ៣០ ថ្ងៃ | រហូតដល់មានការអនុញ្ញាតថ្មី |
| ២ | លិខិតអនុញ្ញាតបដិប្បញ្ញត្តិដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ១, ០០០,០០០ | ៣០ ថ្ងៃ | តែ ១ លើក |
| ៣ | លិខិតស្នើសុំពន្យារការបញ្ចប់ការងារសវនកម្មឯករាជ្យ | ២០០,០០០ | ១៥ ថ្ងៃ | តែ ១ លើក |

# ៥. តម្លៃសេវាសាធារណៈ (ត)

| ល.រ | ប្រភេទសេវា | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៣ | សេវាទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុ | | | |
| | ៣.១ អង្គភាពមិនស្វែងរកប្រាក់ចំណេញជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ១០០,០០០ | ៣០ ថ្ងៃ | ១ ឆ្នាំ |
| | ៣.១ អង្គភាពមិនស្វែងរកប្រាក់ចំណេញជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ៦០,០០០ | ៣០ ថ្ងៃ | ១ ឆ្នាំ |

## ទំព័រ Facebook របស់ ន.គ.ស.




## គេហទំព័រ របស់ ន.គ.ស.






តេឡេក្រាម ព័ត៌មានគណនេយ្យនិងសវនកម្មកម្ពុជា

# សូមអរគុណ